- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ របស់រាជរដ្ឋាភិបាលស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** : អនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១ ( ចំណាយឥតគ្រោងទុក ) នៃថវិការដ្ឋ ចំនួន ៣៨៣.៥០០.០០០,០០ រៀល ( បីរយប៉ែតសិបបីលានប្រាំរយពាន់រៀលគត់ ) បញ្ចូលទៅ ជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងជួសជុលតូច ) របស់ក្រសួងផែនការ ។

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខ និង ត្រា | ហត្ថលេខ និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ២៨ អនក្រ.បក

## ស្តីពី

## បែបបទសំរាប់អនុវត្តចំពោះ ការអនុញ្ញាតអោយជនបរទេស មិនមែនអន្តោប្រវេសន្ត ចេញ ចូល និង ស្នាក់អាស្រ័យនៅ ព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត ១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

### សំរេច

### ជំពូកទី១

### បទបញ្ញត្តិទូទៅ

មាត្រា ១ : អនុក្រឹត្យនេះ កំណត់អំពីបែបបទសំរាប់ការចេញ ចូល និងការស្នាក់អាស្រ័យនៅព្រះរាជាណាចក្រកម្ពុជា នៃជនបរទេសមិនមែនអន្តោប្រវេសន្តដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ លើកលែងតែជនបរទេសរស់នៅតាមតំបន់ព្រំប្រទល់ជាប់ នឹងខេត្តនានា នៃព្រះរាជាណាចក្រកម្ពុជា ដែលជាកម្មវត្ថុ នៃអនុក្រឹត្យដោយឡែក ។

## ជំពូកទី២

## បែបបទសំរាប់ការចេញ ចូល ព្រះរាជាណាចក្រកម្ពុជា

មាត្រា ២ : ជនបរទេស មិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលមានបំណងចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំទិដ្ឋាការចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈអាជ្ញាធរទូត ឬកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬតាមរយៈអាជ្ញាធរបរទេសណាមួយ ដែលតំណាងអោយផលប្រយោជន៍នៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ។

តែចំពោះអ្នកទេសចរ យានិក នាវិក អ្នកដំណើរឆ្លងកាត់ អាចធ្វើពាក្យសុំនៅនឹងចំណុចច្រកទ្វារអន្តរជាតិណាមួយដែលកំណត់ដោយរាជរដ្ឋាភិបាល ។

ជនបរទេសដូចមានចែងខាងលើ ត្រូវបំពេញបែបបទដូចតទៅ ÷

១-ត្រូវបំពេញបែបបទសុំទិដ្ឋាការ ។

២-បង្ហាញលិខិតឆ្លងដែនរបស់ខ្លួន ឬ ឯកសារណាមួយ មានតម្លៃស្មើគ្នានិង ដែលមានសុពលភាពយ៉ាងតិច ៦ ខែ មុនថ្ងៃចូលព្រះរាជាណាចក្រកម្ពុជា ។

៣-ផ្តល់រូបថត ៤ × ៦ ចំនួនពាសន្លឹក « ថតចំពីមុខគ្មានពាក់មួក ឬ វ៉ែនតាពណ៌ » ។

៤-ត្រូវបង់ថ្លៃអាករទិដ្ឋាការ តាមការកំណត់ដូចមានចែងក្នុងមាត្រា ៦ នៃអនុក្រឹត្យនេះ អាករទិដ្ឋាការនេះមិនត្រូវបានសងវិញទេ ទោះក្នុងករណីទិដ្ឋាការនោះបានត្រូវបដិសេធក៏ដោយ ។

កុមារអាយុ ១២ ឆ្នាំ ចុះធ្វើដំណើរជាមួយឱពុក ម្តាយឬអាណាព្យាបាល មិនចាំបាច់បំពេញបែបបទដោយឡែកទេ តែត្រូវចុះឈ្មោះរួមជាមួយឱពុក ម្តាយ ឬ អាណាព្យាបាលរបស់ខ្លួន ។

## ជំពូកទី៣

## ប្រភេទទិដ្ឋាការ រយៈពេល និង ថ្លៃទិដ្ឋាការ

**មាត្រា ៣ :** ទិដ្ឋាការ អាចជាទិដ្ឋាការប្រើសំរាប់ចេញ ចូល តែម្តងគត់ ឬ ច្រើនដង ។ ប្រភេទនៃទិដ្ឋា ការមានដូចខាងក្រោមនេះ ÷

១- ទិដ្ឋាការ ទូត កំណត់សំគាល់ដោយអក្សរធំ (A) ។ ទិដ្ឋាការនេះសំរាប់ផ្តល់អោយចំពោះ ជនបរទេសមិនមែនអន្តោប្រវេសន្ត និង ក្រុមគ្រួសាររបស់គេ កាន់លិខិតឆ្លងដែនការទូតហើយមក បំពេញបេសកកម្មការទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬអាចត្រូវបានផ្តល់ជូនជនបរទេសដទៃទៀត ដែលមានការសំរេចពីរាជរដ្ឋាភិបាល ។

២-ទិដ្ឋាការផ្លូវការ កំណត់សំគាល់ដោយអក្សរធំ (B) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេ ដែលមកបំពេញបេសកកម្មក្នុងក្របខ័ណ្ឌរដ្ឋ អង្គការអន្តរជាតិនានា ដែលមានការទទួលស្គាល់ពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

៣-ទិដ្ឋាការសេរីភាព កំណត់សំគាល់ដោយអក្សរធំ (C) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូន ជនបរទេសមិនមែនអន្តោប្រវេសន្តព្រមទាំងក្រុមគ្រួសាររបស់គេដែលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬក្រសួងនានា ចាត់ទុកថាជាការសំដែងនូវ ការគួរសម ។

៤–ទិដ្ឋាការកិច្ចការពាណិជ្ជកម្ម កំណត់ដោយអក្សរធំ(D)។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្តទាំងឡាយណា ដែលចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងនាមជាអ្នកតំណាងពាណិជ្ជកម្ម ធនាគារឬ

ជាជនដែលមានមុខជំនាញវិជ្ជាជីវៈផ្សេង ។ ដែលចូលមកក្នុងគោលបំណងធ្វើទំនាក់ទំនងក្នុងកិច្ចការជំនាញ ឬ សិក្សាស្រាវជ្រាវក្នុងក្របខ័ណ្ឌវិនិយោគ ។

៥- ទិដ្ឋាការកំណត់ដោយអក្សរធំ ( E ) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសារ ដែលមានបំណងចូលមកព្រះរាជាណាចក្រកម្ពុជា ដើម្បីសួរសុខទុក្ខសាច់ញាតិ និង មិត្តភក្តិ ឬដែលត្រូវគេអញ្ជើញអោយមកចូលរួមនៅក្នុងអង្គសិក្ខាសាលា សន្និសីទ ឬ នៅក្នុងពិធីផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦–ទិដ្ឋាការសារពត៌មាន កំណត់សំគាល់ដោយអក្សរធំ (F)។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្តព្រមទាំងក្រុមគ្រួសាររបស់គេដែលជាអ្នកសារពត៌ អ្នកបោះផ្សាយ ព្រឹត្តិប័ត្រ អ្នកឆ្លើយឆ្លងពត៌មាន ក្រុមវិទ្យុ និង ទូរទស្សន៍ ។

៧–ទិដ្ឋាការសិក្សាស្រាវជ្រាវ និងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគកំណត់សំគាល់ដោយអក្សរធំ (G) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេស មិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលចូលមក ដើម្បីធ្វើការសិក្សាស្រាវជ្រាវ និងកម្មសិក្សាឬមកបង្ហាត់បង្រៀនតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល ។

៨–ទិដ្ឋាការនិយោជិត កំណត់សំគាល់ដោយអក្សរធំ ( H ) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ព្រមទាំងក្រុមគ្រួសាររបស់គេដែលមកធ្វើការនៅតាមរោងចក្រ សហគ្រាសសិប្បកម្ម ឬការដ្ឋានផ្សេងៗដែលមានកិច្ចសន្យាការងារ ។

៩–ទិដ្ឋាការសាសនា និងកិច្ចការសង្គម កំណត់សំគាល់ដោយអក្សរធំ (I) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលចូលមកដើម្បីប្រាស្រ័យទាក់ទងខាងកិច្ចការសាសនា និងកិច្ចការសង្គមដូចជាមកសំដែងសិល្បៈតូរ្យតន្ត្រី ឬ កីឡា ឬ មកក្នុងឋានៈជាអង្គការក្រៅ

រដ្ឋាភិបាល ឬ សមាគមនានា ។

១០–ទិដ្ឋាការទេសចរណ៍ កំណត់សំគាល់ដោយអក្សរធំ ( J ) ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ ជូនជនបរទេសមិនមែនអន្តោប្រវេសន្តអ្នកទេសចរ ។

១១–ទិដ្ឋាការយានិក នាវិក និងឆ្លងកាត់កំណត់សំគាល់ដោយអក្សរធំ (K) ។ ទិដ្ឋាការនេះ សំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលជាអ្នកបើកបរ បុគ្គលិក កម្មករនាវា ឬ យន្តហោះ ។

១២–ទិដ្ឋាការធម្មតា កំណត់សំគាល់ដោយអក្សរធំ (L) ។ ទិដ្ឋាការនេះសំរាប់ផ្តល់ជូនជនបរទេសមិនមែនអន្តោប្រវេសន្ត ទាំងឡាយណាដែលគ្មានរាប់ចូលក្នុងប្រភេទណាមួយដូចខាងលើនេះ ។

**មាត្រា ៤** : រយៈពេលអនុញ្ញាតអោយប្រើប្រាស់ទិដ្ឋាការគ្រប់ប្រភេទត្រូវកំណត់៣ ខែចាប់តាំងពីថ្ងៃចេញទិដ្ឋាការនោះ ។ ផុតរយៈពេល ៣ ខែនេះត្រូវសុំទិដ្ឋាការថ្មី ។ រយៈពេលស្នាក់នៅ ដែលត្រូវបានអនុញ្ញាតជនបរទេសបានចូលព្រះរាជាណាចក្រកម្ពុជា តាមរយៈទិដ្ឋាការដែលផ្តល់ដំបូងជាទូទៅអាចស្នាក់នៅ ១ ខែ ។ ប៉ុន្តែរយៈពេលស្នាក់នេះអាច អនុញ្ញាត ៦ ខែ ចំពោះទិដ្ឋាការទូត ឬផ្លូវការ ។ អាចស្នាក់នៅបាន ៧ ថ្ងៃចំពោះទិដ្ឋាការយានិក និង ឆ្លងកាត់ ។ ការបន្តរយៈពេលស្នាក់នៅត្រូវអនុវត្តតាមការកំណត់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យ នេះ ។

**មាត្រា ៥** : មូលហេតុនៃការស្នាក់នៅជាក់ស្តែង ត្រូវតែស្របតាមប្រភេទនៃទិដ្ឋាការដែលចេញអោយ ។

**មាត្រា ៦** : ថ្លៃអាករទិដ្ឋាការត្រូវកំណត់ដូចខាងក្រោម ÷

| | | |
|---|---|---|
| –ទិដ្ឋាការ ទូត | ( A ) | 00៛,00 |
| –ទិដ្ឋាការ ផ្លូវការ | ( B ) | 00៛,00 |
| –ទិដ្ឋាការ មេត្រីភាព | ( C ) | 00៛,00 |
| –ទិដ្ឋាការ កិច្ចការពាណិជ្ជកម្ម | ( D ) | ៦0.000៛,00 |
| –ទិដ្ឋាការ សួរសុខទុក្ខ | ( E ) | ៦0.000៛,00 |

–ទិដ្ឋាការ សារពត៌មាន ( F) ៦០.០០០៛,០០

–ទិដ្ឋាការ សិក្សាស្រាវជ្រាវ និងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគ

( G) ០០៛,០០

–ទិដ្ឋាការ និយោជិត ( H) ៥០.០០០៛,០០

–ទិដ្ឋាការ សាសនានិងកិច្ចការសង្គម ( I ) ៥០.០០០៛,០០

–ទិដ្ឋាការ ទេសចរណ៍ ( J) ៥០.០០០៛,០០

–ទិដ្ឋាការ យានិក នាវិក និង ឆ្លងកាត់ ( K) ៥០.០០០៛,០០

–ទិដ្ឋាការ ធម្មតា ( L) ៥០.០០០៛,០០

ថ្លៃអាករទិដ្ឋាការនេះអាចបង់ជារូបិយប័ណ្ណបរទេស ដែលមានតម្លៃស្មើគ្នានឹងថ្លៃ អាករទិដ្ឋាការជាប្រាក់រៀល ដែលកំណត់ខាងលើ ។

## ជំពូកទី៤

## ការចេញ ការពន្យារ និង ការបដិសេធទិដ្ឋាការ

**មាត្រា ៧** : ទិដ្ឋាការអាចពន្យារបានដូចតទៅ ÷

– ចំពោះទិដ្ឋាការ ការទូត ( A) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ ផ្លូវការ ( B) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ សេរីភាព ( C) អាចពន្យារបាន ៣ ខែ

– ចំពោះទិដ្ឋាការ កិច្ចការពាណិជ្ជកម្ម ( D) អាចពន្យារបាន ៦ ខែ

– ចំពោះទិដ្ឋាការ សួរសុខទុក្ខ ( E) អាចពន្យារបាន ៣ ខែ « បានតែម្តងគត់ »

– ចំពោះទិដ្ឋាការ សារពត៌មាន ( F) អាចពន្យារបាន ៦ ខែ

– ចំពោះទិដ្ឋាការសិក្សាស្រាវជ្រាវនិងកម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគ (G) អាចពន្យារបាន ១២ ខែ

– ចំពោះទិដ្ឋាការ និយោជិត ( H) អាចពន្យារបាន ១២ ខែ

- ចំពោះទិដ្ឋាការ សាសនា និងកិច្ចការសង្គម ( I) អាចពន្យារបាន ៣ ខែ «បានតែម្តងគត់ »
- ចំពោះទិដ្ឋាការទេសចរណ៍ (J) អាចពន្យារបាន ៣ ខែ «បានតែម្តងគត់ »
- ចំពោះទិដ្ឋាការយានិក និងនាវិក ឆ្លងកាត់ ( K) មិនអាចពន្យារបានទេ លើកលែងតែករណីប្រធានស័ក្តិ
- ចំពោះទិដ្ឋាការធម្មតា (L) អាចពន្យារបាន ៣ ខែ « បានតែម្តងគត់ »

**មាត្រា ៨** : បែបបទនៃការពន្យារទិដ្ឋាការមានដូចតទៅ ÷

១-បំពេញពាក្យសុំពន្យារទិដ្ឋាការ

២-ភ្ជាប់មកជាមួយនូវលិខិតឆ្លងដែន ដែលនៅមានសុពលភាព លើសរយៈពេលស្នើសុំ ស្នាក់នៅ ៣ ខែ ។

៣-រូបថត ៤ × ៦ ចំនួន ០១ សន្លឹក ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌ ។

៤-ត្រូវបង់ថ្លៃអាករពន្យារទិដ្ឋាការតាមការកំណត់ក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ ។

៥-អាចស្នើសុំពន្យារពេលស្នាក់នៅលើសពី ៦ខែ បានចំពោះតែទិដ្ឋាការណាដែលគ្មានចំណារថាពន្យារ «បានតែម្តងគត់ » ប៉ុន្តែត្រូវមានលិខិតបញ្ជាក់ដូចតទៅ ÷

- លិខិតអនុញ្ញាតអោយធ្វើពាណិជ្ជកម្ម ចេញអោយដោយក្រសួងមានសមត្ថកិច្ច ឬ
- លិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ចណាមួយដែលខ្លួនមានទំនាក់ទំនងការងារជាមួយដោយបញ្ជាក់ថា «ពិតជាមានការចាំបាច់ដើម្បីបន្តទិដ្ឋាការមែន » ឬ
- កិច្ចសន្យាការងារជាមួយប្រធានរោងចក្រ សហគ្រាស សិប្បកម្ម ឬការដ្ឋានដែលទទួល ស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

**មាត្រា ៩** : អាជ្ញាធរទូត ឬ កុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជានៅក្រៅប្រទេស ឬ ស្ថានតំណាងព្រះរាជាណាចក្រកម្ពុជានៅបរទេសមានសមត្ថកិច្ច ចេញទិដ្ឋាការគ្រប់ប្រភេទ ។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិមានសមត្ថកិច្ចចេញ ពន្យារ និង បដិសេធទិដ្ឋាការចំពោះប្រភេទទិដ្ឋាការ÷

-ទិដ្ឋាការ ទូត ( A)

-ទិដ្ឋាការ ផ្លូវការ ( B)

-ទិដ្ឋាការ ចៅរីភាព ( C)

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចកិច្ចចេញ ពន្យារ និង បដិសេធទិដ្ឋាការចំពោះប្រភេទទិដ្ឋាការ ដទៃទៀត ។

**មាត្រា ១០** : អាករលើការពន្យារទិដ្ឋាការ ត្រូវកំណត់ដូចខាងក្រោម ÷

១-៧៥.០០០រ,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ១ ខែ ។

២-១៥០.០០០រ,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ៣ ខែ ។

៣-២៥០.០០០រ,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ៦ ខែ ។

៤-៣៧៥.០០០រ,០០ សំរាប់ការសុំពន្យារទិដ្ឋាការរយៈពេល ១២ ខែ ។

អាករលើការពន្យារពេលទិដ្ឋាការខាងលើនេះ មិនអនុវត្តលើការពន្យារទិដ្ឋាការចំពោះទិដ្ឋាការទូត ទិដ្ឋាការផ្លូវការ និងទិដ្ឋាការចៅរីភាព និងទិដ្ឋាការសិក្សាស្រាវជ្រាវ និង កម្មសិក្សាក្រៅក្របខ័ណ្ឌវិនិយោគ ។

**មាត្រា ១១** : អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

## ជំពូកទី៥

## ទោសប្បញ្ញត្តិ

**មាត្រា ១២** : ជនបរទេសមិនមែនអន្តោប្រវេសន្ត ដែលស្នាក់នៅហួសរយៈពេលកំណត់

ត្រូវបង្ខំអោយបង់ប្រាក់ពិន័យរដ្ឋបាល ៧.៥០០រ,០០ ក្នុងមួយថ្ងៃ សំរាប់ថ្ងៃដែលលើសបូកនឹងអាករបើការពន្យារទិដ្ឋាការរយៈពេល ១ ខែ (៧.៥០០រ × ចំនួនថ្ងៃដែលលើស + ៧៥.០០០រ,០០ ) ។

**មាត្រា ១៣** : ១-ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលស្នាក់នៅហួសរយៈពេលកំណត់លើសពី ៣០ ថ្ងៃ ត្រូវបង្ខំអោយបង់ប្រាក់ពិន័យដោយអនុលោមទៅតាមមាត្រា ១២ នៃអនុក្រឹត្យនេះ ហើយត្រូវបញ្ជាអោយចេញពីកម្ពុជាក្នុងរយៈពេល ៧ ថ្ងៃ ។

២-ក្នុងករណីរឹងរូស ឬ គេចវេសមិនចេញពីកម្ពុជាតាមកំណត់ដូចមានចែងក្នុងចំណុចទី ១ នៃមាត្រានេះសាមីខ្លួនត្រូវបង្ខំអោយបង់ប្រាក់ពិន័យទ្វេគុណ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែប បទបណ្តេញចេញតាមច្បាប់ស្តីពីអន្តោប្រវេសន៍ ។

**មាត្រា ១៤** : ជនបរទេសមិនមែនអន្តោប្រវេសន្តណា ដែលល្មើសនឹងមាត្រា ៥ នៃអនុក្រឹត្យនេះ ហើយដែលសកម្មភាពផ្ទាល់បង្ហាញ ថាបានប្រើប្រាស់ទិដ្ឋាការខុសពីប្រភេទដែលបានស្នើសុំ ត្រូវពិន័យអន្តរការណ៍ ជាប្រាក់ ១២៥.០០០រ ហើយត្រូវបណ្តេញចេញ អោយផុតពីព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេល ៧ ថ្ងៃ បើពុំនោះត្រូវពិន័យទ្វេរ ហើយត្រូវឃាត់ខ្លួនដើម្បីរៀបចំបែបបទបណ្តេញចេញតាមច្បាប់ស្តីពី អន្តោប្រវេសន៍ ។

**មាត្រា ១៥** : ប្រាក់ពិន័យខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។

បែបបទនៃការប្រមូលប្រាក់ពិន័យនេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

## ជំពូកទី៦

## ការហាមឃាត់ និង ការបដិសេធទិដ្ឋាការ

**មាត្រា ១៦** : ទិដ្ឋាការគ្រប់ប្រភេទពុំអាចផ្តល់ទៅជនបរទេសមិនមែនអន្តោប្រវេសន្តដែល÷

១-មិនអាចចិញ្ចឹមខ្លួនឯង និងក្រុមគ្រួសារខ្លួន ហើយដែលគ្មានជនណាផ្សេង

សន្យារដោះស្រាយជំនួស ។

២–ប្រកបរបរពេស្យាចារ នាំភៀវអោយជនពេស្យាចារ ឬ ជំនួញពេស្យាកម្ម ផ្សេងៗទៀត។

៣–ពាក់ព័ន្ធនឹងជំនួញគ្រឿងញៀន ដោយខុសច្បាប់ ។

៤–ត្រូវកាត់ទោសពីការប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក្នុងប្រទេសរបស់ខ្លួន ។

៥–ព្រះរាជាណាចក្រកម្ពុជា បានបណ្តេញចេញ ។

៦–បានលួចឡើងជិះនាវា ឬ យន្តហោះ

៧–ព្រះរាជាណាចក្រកម្ពុជា យល់ឃើញមិនចង់អោយមានវត្តមាននៅកម្ពុជា ។

៨–ស្វែងរកទិដ្ឋាការកម្ពុជា ដើម្បីគេចវេះពីច្បាប់នៃប្រទេសដើមរបស់ខ្លួន ។

**មាត្រា ១៧** : រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អាចបដិសេធចោលនូវ ទិដ្ឋាការដែលបានផ្តល់អោយក្នុងសមត្ថកិច្ចរបស់ខ្លួនបានចំពោះមូលហេតុដូចខាងក្រោម ÷

១–ខ្វាន់ទិដ្ឋាការបានរំលោភលើបទបញ្ញត្តិនានា នៃច្បាប់ស្តីពីអន្តោប្រវេសន៍នៃព្រះរាជា ណាចក្រកម្ពុជា ។

២–ខ្វាន់ទិដ្ឋាការត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ ។

៣–ទិដ្ឋាការដែលបានមកដោយការក្លែងបន្លំ ឬ កោសលុប ។

៤–រដ្ឋមន្ត្រីទាំងពីរ យល់ឃើញថាវត្តមានរបស់ខ្វាន់ទិដ្ឋាការ អាចបង្កអោយមានគ្រោះថ្នាក់ ដល់សន្តិសុខជាតិ ។

## ជំពូកទី៧

## អវសានបញ្ញត្តិ

**មាត្រា ១៨** : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៩** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន

ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះ ហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ព្រះហស្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ២៩ អនក្រ.បក**

**ស្តីពី**

**ថ្លៃអាករលើឯកសារធ្វើដំណើរ លិខិតបើកផ្លូវ**

**ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន និង ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍**

**សំរាប់ជនបរទេសអន្តោប្រវេសន្ត**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត-១០៩៤-៩០ ចុះថ្ងៃទី ៣១ ខែ

តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស-រកត-០១៩៦-០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញ ច្បាប់ស្តីពីអន្តោប្រវេសន៍ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពី ការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តាមការយល់ព្រមនៃគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១** : អាករលើលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ឯកសារធ្វើដំណើរ ចំនួនបីសែនរៀល ( ៣០០.០០០រ,០០ ) ។

ខ-លិខិតបើកផ្លូវ ចំនួនប្រាំម៉ឺនរៀល ( ៥០.០០០រ,០០ ) ។

**មាត្រា ២** : អាករលើការពន្យារលិខិតធ្វើដំណើរត្រូវកំណត់ដូចខាងក្រោម :

ក-ការពន្យាពេលឯកសារធ្វើដំណើ ចំនួនប្រាំម៉ឺនរៀល ( ៥០.០០០រ,០០ )

ខ-ការពន្យារពេលលិខិតបើកផ្លូវ ចំនួនបីម៉ឺនប្រាំពីរពាន់ប្រាំរយរៀល (៣៧.៥០០រ,០០) ។

**មាត្រា ៣** : កុមារទាំងពីរភេទមានអាយុ ១២ ឆ្នាំ ចុះ ដែលរួមដំណើរជាមួយឪពុក ម្តាយ ឬ អាណាព្យាបាល ត្រូវបានរួចអាករ ។

**មាត្រា ៤** : អាករលើប័ណ្ណស្នាក់នៅត្រូវកំណត់ដូចខាងក្រោម :

ក-ប័ណ្ណស្នាក់នៅបណ្តោះអាសន្ន ( មានសុពលភាព ១ ឆ្នាំជាអតិបរិមា ) ចំនួនពីរសែន ប្រាំម៉ឺនរៀល ( ២៥០.០០០រ,០០ ) ។

ខ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ( មានសុពលភាព ២ ឆ្នាំ ) ចំនួនប្រាំសែនរៀល ( ៥០០.០០០រ,០០ ) ។

គ-ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ទុតិយតាចំនួនប្រាំសែនរៀល(៥០០.០០០រ,០០)។

**មាត្រា ៥** : ថ្លៃអាករលើការពន្យារពេលប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ត្រូវកំណត់ចំនួនប្រាំសែនរៀល ( ៥០០.០០០៛,០០ ) ។

**មាត្រា ៦** : ថ្លៃអាករគ្រប់ប្រភេទខាងលើនេះ ត្រូវបង់ចូលថវិកាជាតិ ។
បែបបទ នៃការប្រមូលអាករនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងមហាផ្ទៃ ។

**មាត្រា ៧** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

## អនុក្រឹត្យលេខ ៣០ អនក្រ.បក

## ស្តីពីបែបបទសំរាប់អនុវត្តចំពោះការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្តចេញ ចូល និង ស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋ មន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២

– បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
– បានឃើញ ព្រះរាជក្រមលេខ ០២ នស- ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
– បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត - ១០៩៤ - ៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញព្រះរាជក្រឹត្យ លេខ នស.រកត - ១០៩៤- ៩០ -៨៣ ចុះថ្ងៃ ទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
– បានឃើញ ព្រះរាជក្រមលេខ នស.រកត - ០១៩៦ - ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើត ក្រសួងមហាផ្ទៃ
– បានឃើញ ច្បាប់ ស្ដីពីអន្តោប្រវេសន្ត ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០៥ ន/ស ៩៤ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៤
– បានឃើញអនុក្រឹត្យ លេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីកាៀបចំ និង ការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ
– តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
– តាមការយល់ព្រម នៃគណៈរដ្ឋមន្ត្រី

**សំរេច**

## ជំពូកទី១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ :** ជនបរទេសអន្តោប្រវេសន្ត គឺជនបរទេសណាដែលបានកំណត់ក្នុងជំពូកទី៣ នៃច្បាប់ ស្ដីពី អន្តោប្រវេសន៍ ។

មាត្រា ២ : អនុក្រឹត្យនេះកំណត់ពីបែបបទ សំរាប់ការអនុញ្ញាតអោយជនបរទេសអន្តោប្រវេសន្ត ចេញ ចូល និងស្នាក់អាស្រ័យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២

## បែបបទក្នុងការសុំចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា

**មាត្រា ៣** : ជនបរទេសដែលមានបំណងមកស្នាក់អាស្រ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាជនបរទេសអន្តោប្រវេសន្ត អាចដាក់ពាក្យសុំបានមកក្រសួងមហាផ្ទៃ តែតាមរយៈអាជ្ញាធរទូត ឬកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ឬតែតាមរយៈអាជ្ញាធរបរទេសណាមួយដែលតំណាងអោយផលប្រយោជន៍ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រៅប្រទេសដោយ ÷

១–ត្រូវបំពេញបែបបទ ទិដ្ឋាការ ។

២–ត្រូវភ្ជាប់មកជាមួយនូវសេចក្តីចំលងលិខិតឆ្លងដែនរបស់ខ្លួន ឬ សេចក្តីចំលងឯកសារធ្វើ ដំណើរណាមួយដែលមានតម្លៃស្មើគ្នា ដែលមានសុពលភាពយ៉ាងតិច ៦ខែ មុនថ្ងៃចូល ព្រះរាជាណាចក្រកម្ពុជា ។

៣-ត្រូវមានរូបថតទំហំ ៤ × ៦ ចំនួន ៣សន្លឹក « ថតចំពីមុខ គ្មានពាក់មួក និងមិនពាក់វ៉ែន តា ពណ៌ ។

៤–ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សុខភាព ចំនួនមួយច្បាប់ ដែលចេញអោយដោយវេជ្ជបណ្ឌិត នៃប្រទេសដើមរបស់ខ្លួន ។ វិញ្ញាបនប័ត្រនេះត្រូវមានកាលបរិច្ឆេទ មិនហួសពី៣ខែ នៅពេលដាក់ពាក្យ ។

៥–ត្រូវមានភស្តុតាងបញ្ជាក់អំពីការមានមធ្យោបាយគ្រប់គ្រាន់សំរាប់ចិញ្ចឹមជីវិតផ្ទាល់ខ្លួន និង សមាជិកក្នុងបន្ទុកខ្លួនបាន និងមានអ្នកធានាក្នុងស្រុកដែលមានសមត្ថភាព និង លទ្ធភាពទទួលខុសត្រូវខាងជីវភាព និងមធ្យោ-បាយ ផ្គត់ផ្គង់ផ្សេងៗទៀត ។

៦–ត្រូវមានលិខិតថ្កោលទោស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើម របស់ខ្លួន ។

៧–ត្រូវមានសេចក្តីចម្លងកិច្ចសន្យាការងារជាមួយឯកជន ដែលមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជាមួយច្បាប់ បើសិនជាមាន ។

៨–ត្រូវមានសលាកប័ត្រ ស្តីពីការតម្កល់ប្រាក់ធានាសំរាប់ថ្លៃសោហ៊ុយធ្វើដំណើរត្រឡប់ទៅវិញ ឬមាតុភូមិនិវត្តន៍ ជាយថាហេតុចំពោះ ÷

ក–ជនបរទេសដែលមកពីប្រទេស ដែលមានព្រំប្រទល់ជាប់នឹងព្រះរាជាណាចក្រកម្ពុជា ចំនួន ប្រាំសែនរៀល ( ៥០០.០០០៛០០ ) ។

ខ–ជនបរទេស ដែលមកពីអាស៊ី និង អូសេអានី ចំនួន មួយលានពីរសែនប្រាំម៉ឺនរៀល (១.២៥០.០០០៛០០ )

គ–ជនបរទេស ដែលមកពីមជ្ឈិមបូព៌ា និង អាហ្វ្រិក ចំនួន ពីរលានប្រាំសែនរៀល (២.៥០០.០០០ ៛០០ )

ឃ–ជនបរទេស ដែលមកពីអឺរ៉ុប និង អាមេរិក ចំនួន បីលានប្រាំពីរសែនប្រាំម៉ឺនរៀល ( ៣.៧៥០.០០០ ៛០០ )

ប្រាក់នេះត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ហើយអាចដកវិញបានលុះណាតែមានការ អនុញ្ញាតពីក្រសួងមហាផ្ទៃ ។

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន អាយុតិចជាង ១៨ ឆ្នាំ មានបំណងស្នើសុំជាជនបរទេសអន្តោប្រវេសន្តអាចធ្វើពាក្យស្នើសុំនោះជាចង្កោមគ្រួសារ ។

ក្នុងករណីពាក្យស្នើសុំនោះបានទទួលការយល់ព្រម សាមីជនត្រូវបង់ថ្លៃអាករទិដ្ឋាការចំនួន ពីរសែនប្រាំម៉ឺនរៀល(២៥០.០០០៛០០)ក្នុងសមាជិកគ្រួសារម្នាក់ៗ លើកលែងតែកុមារអាយុ ១២ ឆ្នាំចុះ ត្រូវបង់ចំនួន មួយសែនពីរម៉ឺនប្រាំពាន់រៀល ( ១២៥.០០០៛០០ ) ក្នុងកុមារម្នាក់ៗ ។

**មាត្រា ៤ :** អនីតិជន សហព័ទ្ធដែលរួមរស់ជាមួយគ្នា និង អាស្រ័យពឹងពាក់គ្នាខាងផ្លូវកាយ និងខាងហិរញ្ញវត្ថុ ក្នុងលក្ខណៈជាសមាជិកគ្រួសារយ៉ាងជិតស្និទ្ធ ក៏អាចត្រូវទទួលបានការអនុញ្ញាតអោយធ្វើ អន្តោប្រវេសន្តបានដែរ នៅពេលដែល

ជនបរទេសអន្តោប្រវេសន្តណាមួយត្រូវបានទទួល ស្គាល់ហើយនោះ ។

**មាត្រា ៥** : ការទទួលស្គាល់ជនបរទេសណាមួយជាជនអន្តោប្រវេសន្ត ត្រូវសំរេចដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ។

## ជំពូកទី៣

## ការស្នាក់នៅ ការងារ និង ការចេញ ចូល

**មាត្រា ៦** : ជនបរទេសដែលត្រូវបានទទួលស្គាល់ ជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវសុំប័ណ្ណស្នាក់នៅ នៅការិយាល័យជនបរទេស នៃស្នងការដ្ឋាននគរ បាលខេត្ត ក្រុង ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីបានមកដល់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៧** : ជនបរទេសអន្តោប្រវេសន្ត ត្រូវសុំប័ណ្ណការងារតាមការកំណត់នៃច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៨** : ជនបរទេសអន្តោប្រវេសន្ត ដែលមានបំណងចាកចេញពី ព្រះរាជាណាចក្រកម្ពុជា ជាបណ្ដោះ អាសន្នត្រូវសុំការអនុញ្ញាតពីក្រសួងមហាផ្ទៃ ។ បែបបទនៃការស្នើសុំមានដូចតទៅ ÷

១- ត្រូវបំពេញពាក្យសុំចេញពីព្រះរាជាណាចក្រកម្ពុជា តាមរយៈស្នងការនគរបាលខេត្ត ក្រុង ។

២-ត្រូវភ្ជាប់មកជាមួយនូវសេចក្ដីចម្លងលិខិតឆ្លងដែនរបស់ខ្លួន ឬសេចក្ដីចម្លងឯកសារធ្វើដំណើរ ។

៣-ត្រូវផ្ដល់លិខិតថតចម្លងប័ណ្ណស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួនមួយច្បាប់ ។

៤- រូបថតទំហំ ៤ × ៦ មួយសន្លឹក « ថតចំពីមុខ គ្មានពាក់មួក និង វ៉ែនតាពណ៌ » ។

៥- ត្រូវបង់អាករទិដ្ឋាការចេញ - ចូល មួយលើកចំនួនប្រាំម៉ឺនរៀល (៥០.០០០៛០០ )

កុមារមានអាយុ ១២ឆ្នាំចុះ ធ្វើដំណើរជាមួយឪពុក ម្ដាយ ឬ អាណាព្យាបាលមិនបាច់បំពេញ បែបបទដោយឡែកទេ តែត្រូវចុះឈ្មោះ និង បិទរូបថតជាមួយ ឪពុក ម្ដាយ ឬអាណាព្យាបាល ។ កុមារជាអនីតិជន ដែលធ្វើដំណើរទោលតែឯង ត្រូវបង្ហាញលិខិតអនុញ្ញាតិអោយចេញ ដែលចុះ ហត្ថលេខាដោយអាណាព្យាបាល ឬ ឪពុក ម្ដាយស្រប ច្បាប់របស់គេ ។

មាត្រា ៩ : ជនបរទេសអន្តោប្រវេសន្ត ដែលបានបំពេញបែបបទដូចមានចែងក្នុងមាត្រា ៨ ខាងលើ អាចទទួលការបោះត្រា « អនុញ្ញាតអោយចេញ ចូលច្រើនដង » នៅលើលិខិតឆ្លងដែន ឬ ឯកសារធ្វើដំណើរ ។ រយៈពេលនៃការអនុញ្ញាតអោយចេញ ចូលច្រើនដងនោះមិនត្រូវអោយលើសពីបីខែឡើយ ។

អាករទិដ្ឋាការ « អនុញ្ញាតអោយចេញ ចូលច្រើនដងត្រូវកំណត់ » ចំនួនបីសែនរៀល ( ៣០០.០០០ ៛០០ ) ។

មាត្រា ១០ : អាករគ្រប់ប្រភេទខាងលើ ត្រូវបង់ចូលថវិកាជាតិ ។ បែបបទនៃការប្រមូលអាករ នេះត្រូវ កំណត់ដោយប្រកាសអន្តរក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ។

## ជំពូកទី៤

## ការដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត

មាត្រា ១១ : អាចត្រូវដកហូតលក្ខណៈសម្បត្តិជាជនបរទេសអន្តោប្រវេសន្ត ដោយប្រកាសរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលបានប្រព្រឹត្តល្មើស នឹងបទបញ្ញត្តិ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ហើយដែលត្រូវតុលាការផ្ដន្ទាទោសឧក្រិដ្ឋចាប់ពី៥ឆ្នាំឡើងទៅ ។

## ជំពូកទី៥

## អវសានបញ្ញត្តិ

មាត្រា ១២ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតី យុទ្ធជន រដ្ឋលេខាធិការមុខងារសាធារណៈ គ្រប់ប្រធានស្ថាប័ន ដែលមា ការពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុ ហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខា និង ត្រា ហត្ថលេខា និង ត្រា
**នរោត្តម រណឫទ្ធិ** **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៦

**អនុក្រឹត្យលេខ ៣១ អនក្រ.បក**

**ស្តីពីការប្តូរឈ្មោះ « សាកលវិទ្យាល័យភ្នំពេញ »**

**មកជា « សាកលវិទ្យាល័យភូមិន្ទភ្នំពេញ »**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស.រកត ១០៩៤-៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែល ប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤